- ១ -

# បទសម្ភាសន៍ទឹកភ្នែក

**នៅ**ក្នុងបន្ទប់ដ៏ទូលាយសមរម្យល្មមមួយ ដែលមានជញ្ជាំងលាបពណ៌ពងក្រសាខ្ចីស្រទន់ និង ប្រកបដោយបរិក្ខាប្រើប្រាស់សម័យទំនើបសំរាប់ជាទីពេញនិយមរបស់ពួកលោកខាងលិច ។

មិនជាឆ្ងាយពីគ្រែ ដែលមានកម្រាលពូកដ៏សស្គុះដូចសំឡី និង កូនតុដែលតំកល់ផើងតូចដាក់ផ្កាស្រស់ មានរូបថតបួនប្រាំ ខ្លះតំកល់លើខ្នងទូរទស្សន៍ ខ្លះព្យួរនៅជញ្ជាំង ខ្លះដាក់លើតុ និង ខ្លះ ដាក់នៅប្រឡបខ្នើយគេង ។

ប៉ុន្តែ រូបថតដែលមានស៊ុំកញ្ចក់តូចៗ ស្រាលៗទាំងនេះ ហាក់ដូចជាផ្ទុំនៅអែបបង្អួចកញ្ចក់ដែលមានវាំងននដ៏វិចិត្រ និង មានពន្លឺថ្ងៃជះចូលមកយ៉ាងថ្លាស្រឡះ ។

រូបថតទាំងនេះ ប្រហែលជាមិនប៉ុន្មានខែមុនគេឃើញព្យួរយីងរយោងនៅតាមជញ្ជាំងក្នុងផ្ទះជួលមួយម៉ុំផ្សារអូឡាំពិក ក្រុងភ្នំពេញ ហើយអ្នកចេញចូលដែលបានឃើញតែងលាន់មាត់សរសើរថា " ស្អាតណាស់ " មិនដាច់ពីមាត់។ ជាធម្មតាបើកាលណារូបថតស្អាត អ្នកម្ចាស់ក៏តែងតែស្អាតឬស្អាតជាង ? ប៉ុន្តែ ប្លែកតែរូបថតដែលតាំងនៅក្នុងមជ្ឈមណ្ឌលសុខភាពលីន ( LYNN COMMUNILY HEALT CENTER ) នាក្រុងបូស្សតុនរដ្ឋមែស្សាឈូសែតសហរដ្ឋអាមេរិកនេះ ហាក់ដូចជាក្បត់ម្ចាស់រូបទាំងស្រុង ។

គេអាចជឿជាក់ថា រូបថតនេះពិតជាមិនបានដឹងពីសោកនាដកម្ម ដ៏រំជួលចិត្តមួយ កាលពីថ្ងៃទី ០៥ ធ្នូ ១៩៩៩ មកលើម្ចាស់រូប ហើយដែលក្លាយជាព្រឹត្តិការណ៍សិប្បដិភ័យកក្រើករំជួលទូទាំងរាជធានីខ្មែរនោះឡើយ ។ ហេតុនោះហើយទើបរូបថតទាំងនោះ នៅតែមានទឹកមុខស្រស់ស្រាយញញឹមពព្រាយឥតស្រាកស្រុតមកកាន់ស្រីម្នាក់រាងធាត់ល្មមអាយុប្រមាណ៥៤ឆ្នាំជាងបន្តិចបន្តួច និង ស្រីម្នាក់ទៀតធាត់ស្លឹកដូចត្បាល់បុកស្រូវ អាយុប្រហែល ៥០ឆ្នាំផងដែរ ។

នៅអង្គុយក្បែរស្រីទាំងពីរនេះ គឺស្រីម្នាក់ទៀតមានអាយុតិចជាងស្រីទាំងពីរនោះឆ្ងាយ ហើយសុទ្ធតែមានទឹកមុខអន្ទះអន្ទែងរង់ចាំនិងសម្លឹងទៅកាន់រូបថតទាំងប៉ុន្មាននោះឥតសូវលោះខាន ។

មិនដឹងថានារីទាំងបីនេះ រង់ចាំអស់ពេលប៉ុន្មានទៅហើយទេ បានជាឧស្សាហ៍លើកនាឡិកាដៃមើលជាញឹកញាប់ និង សម្លឹងមើលទៅលើគ្រែដែលគ្មានមនុស្សដោយដកដង្ហើមធំមិនដាច់ ។

បន្តិចក្រោយ ស្រាប់តែមានស្នូរជើងមនុស្សដើរតំរង់មករកមាត់ទ្វារបន្ទប់នោះ ។ ទើបនារីទាំងបីក៏គ្រលៀសភ្នែកសម្លឹងមើលទៅឃើញបុរសពីរនាក់ ម្នាក់រាងធាត់កន្តាល់សដូចកូនកាត់ចិន ឯម្នាក់ទៀតខ្មៅស្រអែមរាងខ្ពស់មាឌមាំអាយុប្រមាណ ៣០ ឆ្នាំប៉ុណ្ណោះ ក្មេងជាងបុរសទី១ប្រហែលជិត ១០ ឆ្នាំ ។

ពេលចូលមកដល់មាត់ទ្វារបន្ទប់ ស្រាប់តែបុរសធាត់កន្តាល់ចោលភ្នែកក្រឡើតក្រឡាប់ពេញបន្ទប់ ហើយពោលញាប់ៗ ក្រោយដែលសម្លឹង

ឃើញរូបថតម៉ារីណា ÷

- " ...ចុះនាងទៅណាហើយ ? "

បុរសខ្មៅស្រអែម តបដោយញញឹម ÷

- " ..ខ្ញុំបានប្រាប់លោកអំបាញ់មិញហើយតើ ថាថ្ងៃនេះ ម៉ោងថ្មើរ... ណោះ នាងត្រូវវេជ្ជបណ្ឌិតនាំយកទៅពិនិត្យព្យាបាល . . . បើលោកចង់ជួបសម្ភាសន៍ជាមួយនាងយ៉ាងណានោះ ទាល់តែលោករង់ចាំបន្តិច. . នាងនឹងត្រឡប់មកវិញ? "

បុរសនោះងក់ក្បាលទទួលដោយអារម្មណ៍រីករាយ ទើបពោលបន្តក្រោយដែលងាកទៅសម្លឹងស្រីទាំងបី ÷

- " លោក សេគុនដូ! . មុនដំបូងខ្ញុំគិតថានឹងមកសុំសម្ភាសន៍នាង ប្រហែល ២០នាទីប៉ុណ្ណោះ ប៉ុន្តែក្រោយពីឃើញរូបថតនាង ខ្ញុំស្លុតចិត្តនិងមានសេចក្តីសោកស្តាយជាខ្លាំងមិនគួរយុវនារី ដែលមានរូបសម្ផស្សស្រស់ចំប្រប់ដូចនាង បែរជាត្រូវរងគ្រោះយ៉ាងអយុត្តិធម៌ដូច្នេះសោះ ?. "

ឈប់បន្តិច ទើបជននោះពោលបន្តយ៉ាងរហ័សក្រោយដែលសម្លឹងទៅកាន់រូបថតនៅប្រឋខ្មៃយរបស់អ្នកជម្ងឺសាជាថ្មី ÷

- " ឥឡូវ ខ្ញុំសំរេចចិត្តសុំសម្ភាសន៍នាងឱ្យបានយូរជាងនេះ ឱ្យបានស៊ីជម្រៅពីបញ្ហាដែលគេព្រួតគ្នាធ្វើបាបនាងសូមលោក អនុញ្ញាតផងចុះ! . "

សេគុនដូ គ្រាន់តែងក់ក្បាលយល់ព្រមមិនបាននិយាយចេញមកថាដូចម្តេចឡើយ ព្រោះពេលនោះគេរវល់តែងាកមកគួរសមដាក់នារីទាំងបី ហើយស្រីម្នាក់ដែលរាងចំណាស់ជាងគេបន្តិចក៏ចាប់បន្លឺឡើង ÷

-" ..មីងនាំគ្នាមកថ្ងៃនេះទៀត ដើម្បីចង់ដឹងតើគេព្យាបាលស្រីអូន ដល់ណាហើយ តែមកមិនបានជួបត្រូវនៅអង្គុយចាំសិន!.."

បន្តិចនោះ សេគុនដូ បុរសក្មេងដែលមានខ្សែភ្នែកមុះមុតបានឧទានឡើងយឺតៗទៅកាន់ជននោះទៀតថា ÷

-" ..នេះជាមីងៗរបស់ខ្ញុំ និងប្អូនជីដូនមួយខ្ញុំ..គាត់ខ្វល់ខ្វាយណាស់ ពេលដែលឮថាស្រីអូនទទួលរងគ្រោះថ្នាក់ដូច្នេះ ? "

នារីវាងចំណាស់ឈ្មោះ តាត គិមឡេង បានបន្តឃ្លាដោយទឹកមុខព្រួយបារម្ភ ÷

-" ខ្ញុំប្អូនបង្កើតទី៤របស់ឪពុក ម៉ារីណា ទើបមកនៅអាមេរិកនេះបានបួនប្រាំឆ្នាំប៉ុណ្ណោះ ធ្លាប់ឃើញ ម៉ារីណា នៅតូចទៅរៀន សាលាភ្នំដូនពេញឥឡូវវាធំមើលស្ទើរមិនស្គាល់ ហើយស្អាតណាស់ ! . ប៉ុន្តែ មិនគួរវាបានមកដល់ទីនេះដែរ មកក្នុងលក្ខណៈគួរឱ្យរន្ធត់សោកស្តាយបែបនេះសោះ បងប្អូនយើងច្រើនទៀតដែលនៅអាមេរិកនេះ បានមកសួរសុខទុក្ខវាជាបន្តបន្ទាប់ ! ."

នារីធាត់ម្នាក់ទៀត ឈ្មោះ តាត លួម ហៅម៉ាឡា-អ៊ូច ក៏បន្លឺយ៉ាងស្រពាប់ស្រពោនដែរ ÷

-" ឯខ្ញុំជាប្អូនទី៥ ដែលបានមកនៅអាមេរិកនេះយូរហើយ តាំងតែពីឆ្នាំ ៨០-៨១ មុន ម៉ារីណា កើតទៅទៀត! ឥឡូវបានឃើញក្មួយហើយបែរជានាងរងគ្រោះបែបនេះទៅវិញ!. មនុស្សនោះ អីក៏សាហាវព្រៃផ្សៃមិនស្គាល់បុណ្យ ស្គាល់បាប អាងតែមានទ្រព្យសម្បត្តិបុណ្យស័ក្តិរំលោភ

បំពានលើក្មេងស្រី!"

នារីនោះ និយាយដោយបង្ហូតដង្ហើមយ៉ាងវែងនៅចុងបំផុតឃ្លា ធ្វើឱ្យសេគុនដូបន្ថែបន្ថែមទៅកាន់បុរសធាត់កន្ទាល់ទៀតថា ÷

–"..ឯនេះ គឺ ប៊ុនឈឿន សូមីរ៉ែត កូនរបស់ពូខ្ញុំ..ដែលនៅស្រុកខ្មែរ គេមានប្ដីមកនៅក្នុងរដ្ឋនេះដែរ!.."

ជាបន្ទាប់នោះ នារីដែលមានវ័យស្រួបាក់ស្រួបាលនិងសេគុនដូ ក៏ពោលបន្តយឺតៗ របៀបជាមនុស្សមិនសូវចេះនិយាយស្ដី ÷

–" ពេលដែលស្រីអូនមកដល់ភ្លាម ខ្ញុំប្រញាប់ប្រញាល់មកសួរសុខទុក្ខ ដោយនាំផេតទ្រើស្សាកូនស្រីខ្ញុំអាយុ៣ឆ្នាំមកជាមួយផង.. តែពេលនោះ កូនខ្ញុំវាស្រែកញ័ររន្ធត់ ដោយខ្លាចមុខមាត់មីងវា.! ឥឡូវខ្ញុំមិនហ៊ានយកវាមកទៀតទេ!..."

សម្ដី មាណារី ដែលមានអាយុតិចជាងគេ ធ្វើឱ្យបុរសជាភ្ញៀវប្រែប្រួលទឹកមុខចុះឡើងជាច្រើនដង ដែលមិនអាចអ្នកណាស្មានត្រូវថាយ៉ាងណាឡើយ ប៉ុន្តែនៅពេលបន្ទាប់នោះស្នូរសង្កៀតខ្សៀកៗនៃកង់រទេះរុញមួយ បានលាន់ឮឡើងលើកំរាលអិដ្ឋមកពីចម្ងាយ ។

ស្នូរសង្កៀតនេះ ហាក់ដូចជាមានឥទ្ធិពលសង្កត់ស្រិបៗមកលើបេះដូងរបស់អ្នកដែលអង្គុយរង់ចាំ ធ្វើឱ្យគេចាប់ផ្ដើមមានអារម្មណ៍ស៊ើបរំភើបភ្លាមឡើង នៅគ្រាដែលរទេះនោះបានរំកិលចូលមកតាមទ្វារសន្សឹមៗ ដោយគ្រូពេទ្យស្រីអាមេរិកាំងម្នាក់ជាអ្នករុញពីក្រោយ ។

មានសម្លេងមួយត្រូវលាន់ឮឡើងមុនគេ បន្ទាប់ពីបរិយាកាស

ស្ងប់ស្ងាត់មួយរយៈនោះ ÷

-" ម៉ារីណា អូន !. នេះគឺលោក ពៅ ពន្លក អ្នកយកពត៌មានប្រចាំវិទ្យុអាស៊ីសេរីមកសុំសម្ភាសន៍ !."

បុរសដែលទើបបានគេស្គាល់ឈ្មោះ និង មុខងារដ៏សំខាន់នេះ ក្រោកឡើង ដោយភ្ញាក់ផ្អើលពីកៅអីដែលទើបនឹងអង្គុយមិនបានកន្លះដង្ហើមផង ហើយសម្តែងការគោរពយ៉ាងអនោចអធម៌ទៅកាន់ស្រមោលស្រីម្នាក់រាងតូចស្តើងស្ថិតក្នុងសំលៀកបំពាក់អ្នកជម្ងឺ អង្គុយលើកៅអីរុញនោះដោយអាការៈល្ងិតល្ងៃ ។

ទោះបីជាលោក សេគុនដូ ដែលធ្លាប់ឃើញមុខមាត់ដ៏រលេះរលួយរបស់ប្អូនរាល់ថ្ងៃហើយក៏ដោយ ក៏ពេលនោះគេហាក់ដូចជាពិបាកនឹងបើកភ្នែកមើលតទៅទៀតណាស់ ព្រោះអ្វី១ក៏វានៅជាទិដ្ឋភាពគួរឱ្យរន្ធត់ញាប់ញ័រដដែល ។ ចំណែកលោក ពៅ ពន្លក មានអាការៈព្រឺស៊ើបជាងអ្នកណាទាំងអស់ ព្រោះគេមើលទៅឃើញនារីអភ័ព្វនោះគ្មានស្បែកមុខទេ គឺស្បែកមុខបានរលេះរលួយអស់ទៅហើយ ។ ទន្ទឹមនោះខ្ទង់ច្រមុះដែលក្រពិតជាប់ទៅលើសាច់មុខដ៏ក្រហមរងាលស្ទើរមើលប្រហោងរន្ធមិនឃើញ ត្រូវបានគេដោតបំពង់ជ័រពីរ ដើម្បីសម្រួលឱ្យនាងដកដង្ហើមចេញ ចូលបាន ។ បបូរមាត់ខាងលើរបស់នាងរលួយខើចដូចត្រូវគេចាប់ហែក ឯខាងក្រោមវិញសឹងតែរលេះធ្លាក់ចុះដាច់ពីគ្នា ប៉ុន្តែហាក់ដូចជាត្រូវគេរុំក្រណាត់បិទទប់កុំឱ្យវារបេះធ្លាក់មកខ្លាំងពេក ។

ភាពដែលធ្វើឱ្យអ្នកយកពត៌មានវិទ្យុអាស៊ីសេរី ខ្លោចផ្សាក្នុងចិត្ត

មែនទែននោះ គឺត្រចៀកទាំងពីររបស់អ្នកជម្ងឺបានរលេះបាត់ទៅហើយ ។ វាហាក់ដូចជាឃ្លាតឆ្ងាយស្ទើរតែឆ្ងាយពីរូបថត នាងដែលតាំងនៅតាមជញ្ជាំង ហើយក្បាលដែលធ្លាប់មានសក់ខ្មៅវែងអន្ទាយរលកអង្កាញ់ និង ស្លឹកត្រចៀក ទាំងគូធ្លាប់សង្ហារ ដោយរំយោលអាយ៉ាដក់ ឬ បន្តោងអ្វីផ្សេងនោះវាហាក់ ដូចក្លាយទៅជាវាលរហោស្ថានដែលមានតែព្រៃដុះបន្តិចបន្តួច គឺកញ្ចុំសក់ ដែលសល់ពីស្នាមកាំបិតកោរ ហើយសល់តែផ្នែកខាងលើបុំណ្ណោះ ឯផ្នែកខាង ក្រោយរលួយរលេះមើលឃើញដល់សាច់លលាដ៍ក្បាល ។

តាមរយៈរូបភាពដ៏គួរឱ្យរន្ធត់ និង អនោចធម៌នោះ គេអាចស្មាន ត្រូវទេ តើម៉ារីណាបូផាតូចខ្ចីនាងឆ្លងកាត់ការឈឺចាប់ដល់គិរិតណា ហើយ ការព្យាបាលសារចុះសារឡើងតាំងពីស្រុកខ្មែរ រហូតដល់ស្រុកយួន និង រហូតដល់អាមេរិកនេះ តើសតិអារម្មណ៍របស់នាងត្រូវទទួលរងនូវការ វិប្បលាស ត្រឡប់ត្រឡិនសង្កត់ សង្កិនដោយទុក្ខទោមនស្សកម្រិតណាដែរ ? ។

ដោយហេតុមានការខ្លោចផ្សាយ៉ាងនេះហើយ ទើបលោក ពៅ ពន្លក ទំនងជាមិនចង់ហ៊ានសាកសួរនាង ។ ប៉ុន្តែកំលាំងចិត្តមួយបានចូល មកសណ្ឋិតក្នុងខ្លួនបុរសនេះសាជាថ្មី ក្រោយដែលក្រឡេកឃើញស្រីអ្នកជម្ងឺ លើកដៃសំពះយ៉ាងស្រទន់សុភាពមកកាន់អ្នករាល់គ្នា ពិសេសគឺរូបគេផ្ទាល់ តែម្តង ។

គេមិនបានពួសម្លេង ម៉ារីណា ចេញមកជាមួយការលើកដៃសំពះ ថាដូចម្តេចឡើយ ប្រហែលជាបបូរមាត់នោះពិបាកកំរើកក៏មិនដឹង ប៉ុន្តែដើម្បី ឆ្លើយតបនិងកាយវិការជាប្រពៃណីខ្មែរនេះ លោក ពៅ ពន្លក ក៏ចាប់ផ្តើម

និយាយភ្លាមថា ÷

- " ម៉ារីណា មជ្ឈដ្ឋានខ្មែរយើងដែលនៅបរទេសច្រើនណាស់ ចាប់អារម្មណ៍ចំពោះរឿងនាង ហេតុនេះតំណាងឱ្យវិទ្យុអាស៊ីសេរី ខ្ញុំមកសុំសម្ភាសន៍នាងដើម្បីចង់ដឹងពីហេតុការណ៍មួយចំនួន!.."

ម្តងនេះ ទើបសំនៀងស្រាលៗបានរអិលចេញពីបបូរមាត់ដ៏រលេះរលួយដែលពីកាលមុនបបូរមាត់នេះ ប្រៀបបាននឹងក្លែបក្រូចដ៏ពេញដោយទឹកដម ÷

-" ចាំះ តើលោកពូ... ចង់សម្ភាសន៍យ៉ាងណាខ្លះ ? "

ដោយហេតុអ្នកជម្ងឺកំពុងអង្គុយលើរទេះរុញនៅឡើយ ទើបលោក ពៅ ពន្លក ទាញកៅអីដែលនៅក្បែរនោះ មកអង្គុយ ចំពីមុខ ម៉ារីណា និងទាញកូនសៀវភៅកំណត់ហេតុមួយពីក្នុង កាបូបស្ពាយមកត្រៀមសរសេរដោយបង្ហើរប្រយោគបណ្តើរ ÷

-"..រឿងរ៉ាវខ្លះៗដែលគេធ្វើបាបនាង ខ្ញុំបានដឹងជាហូហែតាម កាំបូឡៀវដែល្លី និងកាសែ្សតផ្សេងៗខ្លះហើយ ពេលនេះខ្ញុំគ្រាន់តែចង់ដឹងពីមនោសញ្ចេត-នារបស់នាង បន្ទាប់ពីបានមកព្យាបាលនៅមន្ទីរពេទ្យនេះហើយ នឹងអារម្មណ៍ដក់ជាប់លើទំហំនៃការវាយប្រហារដោយទឹកអាស៊ីដនោះ ? "

ពេលនោះ ទោះបីនារីទាំងបីចង់សំណោះសំណាលលេងជា មួយម៉ារីណាយ៉ាងណា ក៏ត្រូវតែបង្ខំចិត្តនៅស្ងៀមមួយរយៈសិន ដើម្បីរង់ចាំស្តាប់ចំលើយរបស់នារីអភ័ព្វដែលលាន់ឮមកយ៉ាងល្អិតល្ហែស្រួយឆ្មារថា ÷

-"..លោកអើយ!.. ខ្ញុំប៉ុន្មានថ្ងៃនេះ ហាក់ដូចជានឹកស្រុកពន់ពេកណាស់ ព្រោះ

តាំងពីក្មេងមក ខ្ញុំមិនដែលនៅឃ្លាតពីពុកម៉ែ និង បងប្អូនឆ្ងាយដាច់សង្វែងយ៉ាងនេះទេ ប៉ុន្តែចិត្តដែលរំភើបលាយឡំជាមួយសប្បាយរីករាយក៏មានខ្លះដែរ ហើយអ្វីដែលខ្ញុំនៅតែនឹកឃើញនោះ គឺការតក់ស្លុតភ័យរន្ធត់... ដែលមិនអាចបំភ្លេចបាន !..."

ចុងបិចរបស់អ្នកយកព័ត៌មាន ដូចជាមិនទាន់គួសវាសលើក្រដាសយ៉ាងណានៅឡើយ ព្រោះមើលទៅម៉ារីណោទំនងជា ឆ្លើយមិនទាន់ចំសំនួរទើបលោក ពៅ ពន្លក ចាប់ផ្តើមឧទានសាជាថ្មីដោយទឹកមុខញញឹមវាងវៃ ÷

–"..តើនាងនិយាយថា រំភើបសប្បាយនោះយ៉ាងណាដែរ ?"

នៅចន្លោះពេលដែលក្មេងស្រី ហាក់ដូចជាកំពុងរកនឹក នោះសេគុនដូ ដែលឈរនៅក្បែរនោះដែរក៏អោនមុខមកទាបបន្តិច ហើយពោលតិច១ថា ÷

–"... អូនឯងនិយាយប្រាប់លោកឱ្យអស់ទៅ .. ព្រោះវិទ្យុនេះជាសម្លេងដែលឮពេញសកលលោក.. ហើយកុំភ័យថានិយាយនៅទីនេះមានអ្វីហាមឃាត់នោះ ?"

សម្តីនេះ គឺជាកម្លាំងចិត្តដ៏ធំធេងណាស់ដែលល្មមតែជំរុញ ម៉ារីណោឱ្យនិយាយអ្វីតាមចិត្តដែលនាងចង់ ប៉ុន្តែនាងបែរជាមានតំណក់ទឹកថ្លា១ហូរចេញពីត្របកភ្នែកដែលជ្រីវជ្រួញមកមុន ទើបវាចាតិច១មកតាមក្រោយ ÷

–"ពូ! . ខ្ញុំរំភើបសប្បាយ ដោយសារមិននឹកស្រមៃថាបានមកដល់អាមេរិកនេះសោះ អ្វី១សឹងតែមិនគួរឱ្យជឿទៅកើត ប៉ុន្តែស្រាប់តែមានការសោកស្តាយតូចចិត្តខ្លួនឯង ដោយបានមកដល់កន្លែងដ៏កក់ក្តៅនេះ

ហើយ បែរជាខ្ញុំមិនបានដើរលេងសប្បាយដូចគេ បែរជាដេកឈឺនៅទីនេះទៅវិញ ដែលមិនដឹងជាថ្ងៃណានឹងបានជាសះស្បើយទេ ! "

វ៉ាចាតំអូញដ៏គួរឱ្យអាណិតខ្លោចផ្សានេះ វ៉ាមិនសមនឹងស្ថិតនៅក្នុងទំរង់មុខដ៏គួរឱ្យខ្លាចញញើតនោះឡើយ ព្រោះពេលដែលនាងហារនិយាយម្តងៗ បបូរមាត់វៀចចុះវៀចឡើងមិនគួរឱ្យចង់មើល ហើយសម្លេងទៀតសោតក៏ត្បៀតតូចញ្ញសូរង៉េវៗ ដូចជាស្នូរអ្វីមួយក្នុងម៉ាស៊ីន GAMES សំរាប់ក្មេងលេង ។ ទោះបីយ៉ាងនេះក្តី ក៏ពេលនេះយើងឃើញចុងប៊ិចរបស់អ្នកយកពតិមាន ចាប់ផ្តើមធ្វើចលនាគូសវ៉ាសនៅលើក្រដាសសៀវភៅ តាមបែបផែន sténographes យ៉ាងញាប់ស្ទេរ ។

ប្រហែលមិនទាន់ចិត្តក៏មិនដឹង ទើបជននោះបញ្ចេញកូន magnétophone តូចប៉ុនកញ្ចប់បារីពីក្នុង ហោប៉ៅអាវមកទៀត ហើយដាក់លើតុក្បែរនោះ ដែលល្មមតែស្រូបសម្លេងម៉ារីណាបាន ។

នៅពេលដែលឃើញប្រដាប់ថតសម្លេងរុញមកជិត ម៉ារីណា ហាក់ដូចជាមានកម្លាំងចិត្តសារជាថ្មី ហើយបង្ហូរវ៉ាចាលាយឡំជាមួយទឹកភ្នែកថា ÷

- " លោកពូអើយ ! . ទោះបីគេធ្វើបាបលើរាងកាយដល់ក៏រិតនេះ ក៏ដោយក៏ខ្ញុំគិតថាថ្ងៃណាមួយដោយការប៉ិនប្រសប់របស់គ្រូ ពេទ្យអាមេរិកស្នាមរបួសទាំងនេះអាចជាសះបាន ហើយការឈឺចាប់ដែលរលាករលួយនេះក៏អាចបាត់រសាត់ទៅដែរ ប៉ុន្តែ ទារុណកម្មផ្លូវចិត្ត ដែលជាស្រមោលនៃការគៀបសង្កត់មួយនោះ នៅតែដុតរោលជាប់អារម្មណ៍ខ្ញុំឥតទាន់ស្រកស្រុតទៅណាឡើយ វ៉ាធ្វើឱ្យខ្ញុំភ័យរន្ធត់ញាប់ញ័រជាប់ជានិច្ច ! . "

ស្រីទាំងបីរូបដែលនៅអង្គុយក្បែរ ក៏មានអាការៈខ្សឹកខ្សួលអួល អាក់ទៅតាមចង្វាក់ពាក្យរបស់ម៉ារីណាដែលព្ធិតល្វែតទៅទៀតថា ៖

-"..រាល់យប់ ខ្ញុំតែងយល់សប្តិឃើញហេតុការណ៍ទាំងនោះ គឺហេតុការណ៍ថ្ងៃដែលគេព្រួតគ្នាវាយដំ និង ស្រោចទឹកអាស៊ីដ មកលើខ្ញុំ.. ធ្វើឱ្យខ្ញុំរន្ធត់បាក់ស្មារតី ក្រោមសម្លេងស្រែកគំរាមឃោរឃៅព្រៃផ្សៃ !.."

ម៉ារីណា និយាយមកដល់ត្រឹមណោះ ក៏មានទឹកភ្នែកហូរមកកាន់តែច្រើនជាងមុន ធ្វើឱ្យលោក ពៅ ពន្លក ព្យាយាមធ្វើការលួងលោមថា ៖

-"..ប៉ុន្តែពេលនេះ ពួកអមនុស្សធម៌នោះ លែងមានលទ្ធភាពមកធ្វើបាបនាងទៀតហើយ !."

ដោយឃើញម៉ារីណា គ្រាន់តែងក់ក្បាលទទួលក្នុងអាការៈហត់ហេវនោះ អ្នកគ្រូពេទ្យអាមេរិកាំងក៏និយាយទៅកាន់អ្នកយកពត៌មាននេះជាភាសាអាមេរិកដែលន័យថា ៖

-"..ប៉ុណ្ណឹងចុះ សូមទុកឱ្យម៉ារីណាសំរាកសិន !."

នៅពេលដែលម្តាយមីង និង បងនាងជួយគ្រាហ៍នាងចេញពីរទេះរុញដាក់ទៅលើគ្រែ លោក ពៅ ពន្លក ក៏ឆ្លៀតងាកមកសួរគ្រូពេទ្យស្រីនោះថា ៖

-"..តើស្ថានភាពជម្ងឺរបស់នាងយ៉ាងណាដែរ ការព្យាបាលអាចមានសង្ឃឹមទៅមុខទេ ?."

គ្រូពេទ្យ តបមកវិញដោយញញឹមគួរទុកចិត្ត ៖

-"..អាការៈរោគរបស់ ម៉ារីណា ធ្ងន់ធ្ងរណាស់ ថ្វីបើនាងនិយាយ បាន និង

ញាំុបាយបាន ប៉ុន្តែភាពផុយរលួយដែលកើតមានពី កម្លាំងជាតិគីមីមក លើស្បែក និង មុខមាត់របស់នាងនៅតែបន្តការជ្រាបចូលតាមកោសិកាផ្សេងៗនៃរាងកាយ បើសិនជាបណ្តោយទុកនាងនៅកន្លែងមួយដែលគ្មានវិធីសាស្ត្រព្យាបាលហ្មត់ចត់ !."

ឮសំដីនេះរបស់គ្រូពេទ្យ ធ្វើឱ្យនារីទាំងនោះគិតថា « បើសិនជាកុំរវើយកទៅព្យាបាលនៅវៀតណាម ហើយប្រញាប់យកមកទីនេះតែម្តង ប្រហែលជាជម្ងឺរបស់នាងមិនធ្ងន់ធ្ងរដល់ថ្នាក់នេះទេ !. »

សេគុនដូ គ្រវីក្បាលមិននិយាយ ដោយការសោកស្តាយនិងហួសចិត្ត ឯ លោក ពៅ ពន្លក ក៏ឆ្លៀតសួរបន្ត ÷

-"..តើគេមិនអាចទប់ស្កាត់ការជ្រាបចូលនៃកម្លាំងមេរោគអាស៊ីដ នោះទៅក្នុងកោសិកាផ្សេងៗបានទេឬយ៉ាងណា ? ឬមួយក៏វាចេះតែបន្តការស៊ីរូងចូលជ្រៅតទៅទៀត ?"

អ្នកគ្រូពេទ្យអាមេរិក ឆ្លើយដោយញញឹមទៀត ÷

-" ក្រុមគ្រូពេទ្យរបស់យើង បានព្យាយាមធ្វើការទប់ស្កាត់កម្លាំងជ្រាបរបស់ជាតិគីមីនោះហើយ សង្ឃឹមថាអ្វីដែលរលេះរលួយនៅលើសរីរាង្គរបស់នាងដូចធ្លាប់ឃើញកន្លងមក វានឹងស្ងួតក្រៀមជាសះស្បើយទៅវិញបាន ប៉ុន្តែប្រការដ៏ដែលសំខាន់ គឺការព្យាបាលមុខមាត់របស់នាងដែលយើងកំពុងតែគិតគូរដោយមធ្យ័តជាទីបំផុត !."

អ្នកយកពតិមានកាន់តែមានការចាប់អារម្មណ៍ ហើយបែរមកសម្លឹងមុខ ម៉ារីណា សាជាថ្មី ក្រោមការពន្យល់របស់គ្រូពេទ្យតទៅទៀត ÷

-" . . ដូចលោកជ្រាបស្រាប់ហើយថា ម៉ារីណាចេញពីស្រុកខ្មែរមកដល់មន្ទីរពេទ្យយើងនេះនៅចុងខែកុម្ភៈទៅហើយ យើងក៏មិនបណ្តែតបណ្តោយឱ្យខាតពេលយូរដែរ គឺក្រោយពីឱ្យនាងសំរាកបានសាំុនឹងអាកាសធាតុនៅទីនេះបន្តិចនៅថ្ងៃទី ០៦ មិនា ក្រុមគ្រូពេទ្យយើងបានចាប់ផ្តើមព្យាបាលមាត់ និង ច្រមុះនាងជាលើកដំបូង ដោយមិនអនុញ្ញាតឱ្យនាងនិយាយច្រើន និង ផ្អាកមិនឱ្យញ៉ាំអាហារ ដូចជា បាយ មួយរយៈសិនដើម្បីឱ្យមាត់មានលក្ខណៈដូចដើមវិញ ឯច្រមុះកំពុងរកវិធីកែលំអឱ្យបានសមរម្យដូចមុនដែរ ! ."

ពេលនោះ សេគុនដូ ក៏ឆ្លៀតបញ្ជាក់ប្រាប់អ្នកយកពត៌មានបន្ថែមថា ÷

-"..ជម្ងឺប្អូនស្រីខ្ញុំនេះ វាអាចអំណោយផលច្រើនណាំលោក! ដោយសារខ្ញុំជានិយោជិកនៅទីនេះស្រាប់! ក្រោយដែលខ្ញុំបានទទួលដំណឹងពីស្រុកខ្មែរថា ប្អូនខ្ញុំត្រូវរងការវាយប្រហារដោយទឹកអាស៊ីដពេលណាខ្ញុំក៏បានខលទៅប្រាប់ឪពុកម្តាយខ្ញុំថា បើសិនជាមុខរបួសនាងធ្ងន់ធ្ងរមិនអាចព្យាបាលនៅទីនោះបាន ខ្ញុំនឹងរកមធ្យោបាយយ៉ាងណាឱ្យប្អូនស្រីខ្ញុំមកព្យាបាលនៅអាមេរិកនេះវិញ ព្រោះទីនេះសម្ភារៈបច្ចេកទេសគេទំនើបជាង ! . ."

ម៉ារីណា ខំសម្ងំស្ងៀមនៅលើគ្រែ ធ្វើភ្នែកភ្លឹស១ ប៉ុន្តែអ្វី១ក្នុងចិត្តថ្លើមរបស់នាងហាក់ដូចជាជ្រួលច្របល់ខ្លាំងណាស់ កាលបើឮបងនាងរំលឹកពីរឿងនាងទើបនឹងរងគ្រោះ ។ ជួនគ្នាពេលនោះ អ្នកស្រី តាត គិមឡេង បាន

ឧទានឡើងដែរថា ÷

-" រឿងនេះក្តួយសុខ (សេគុនដូ ) គេឈ្មុសឈ្មុលណាស់ បើសិនជាល្មមៗការងារនេះមិនបានសំរេចទេ ! .."

យុវបុរសនេះ កាលបើឮម្តាយមីងនិយាយដូច្នេះ គេក៏បញ្ជាក់បន្ថែម ÷

-" មុននឹងខ្ញុំទៅស្រុកខ្មែរ ទៅសួរសុខទុក្ខប្អូនស្រីខ្ញុំ បន្ទាប់ពីគេវាយ ប្រហារនោះ ខ្ញុំក៏បានធ្វើការស្ទាបស្ទង់មតិជាមួយលោក ROSEMARY SARGENT ដែលជាប្រធានមជ្ឈមណ្ឌលនេះ និងជាតំណាងរាស្ត្រប្រចាំតំបន់នេះទៀតផងនោះ លោកក៏បានបង្ហាញនូវសមានចិត្តជួយខ្នះខ្នែងជ្រោមជ្រែងក្នុងរឿងនេះភ្លាម គឺគាត់នឹងព្រមទទួលយក ម៉ារីណា មកព្យាបាលឱ្យតែខ្ញុំធ្វើយ៉ាងណា សុំទិដ្ឋាការពីស្ថានទូតអាមេរិកប្រចាំនៅប្រទេសកម្ពុជាបាន ឯបញ្ហាសោហ៊ុយថ្លៃយន្តហោះសមាគមជួយសង្គ្រោះរបស់មជ្ឈមណ្ឌល LYNN នឹងផ្តល់ឱ្យរួមទាំងវិភាគ ទានពីសប្បុរសជនខ្មែរ និងបរទេសច្រើនទៀត ព្រោះគេគ្រាន់ តែឮដំណឹងពីការវាយប្រហារនេះភ្លាម គេមានការតក់ស្លុត ហើយអាណិត ម៉ារីណា គ្រប់ៗគ្នាព្រោះនាងនៅក្មេងក្នុងវ័យមិនទាន់គ្រប់១៧ឆ្នាំ គេចាត់ទុកជាកុមារីនៅស្រុកគេ ដែលមិនអាចបណ្តោយឱ្យរងអំពើហឹង្សា ដោយមិនយកចិត្តទុកដាក់ជួយព្យាបាលនោះឡើយ ! .."

លោក ពៅ ពន្លក ងក់ក្បាលយឺតៗស្របតាមរលកសម្លេង បន្តរបស់សេគុនដូ ÷

-" នេះសញ្ញាវិជ្ជមានមួយដល់ពេលខ្ញុំទៅដល់ស្រុកខ្មែរ ឃើញប្អូនរលេះរលួយដូចខ្មោចយ៉ាងនេះ ខ្ញុំរន្ធត់ចិត្តណាស់ស្ទើរតែនឹងយកនាងមកទីនេះភ្លាមៗ ប៉ុន្តែដោយរត់ការមិនទាន់ហើយជួន ពេលនោះភាគីខាងមន្ត្រីដែលមានពាក់ពន្ធ័ជាមួយប្អូនខ្ញុំនោះ គេធានាអះអាងថានឹងយកនាងទៅព្យាបាលនៅប្រទេសវៀតណាមវិញ ព្រោះទីនោះជិត ហើយឮថាគ្រូពេទ្យនៅ ឯណោះក៏ពូកែខ្លាំងក្លាណាស់ដែរ ។ នៅពេលនោះ ខ្ញុំក៏បានព្រមព្រៀងជាមួយពុកម៉ែ ថាឱ្យគេនាំនាងទៅព្យាបាលនៅទីនោះសិនចុះដើម្បីឱ្យអស់ចិត្តគេ ហើយដែលខ្ញុំយល់ថានោះ គឺជាការខំលាងទោសកំហុសរបស់ប្រពន្ធគេ ដែលធ្វើមកលើប្អូនស្រីខ្ញុំ។ម្យ៉ាង ដោយខ្ញុំយល់ថាខ្ញុំរត់ការយកនាងមកអាមេរិក នេះមិនទាន់បានដែរ បើទុកនាងនៅក្នុងមន្ទីរពេទ្យលោកសង្ឃួតទៅទៀត មុខជាជម្ងឺនាងមិនដឹងពេលណាបានជាសះស្បើយនោះទេ ។ នេះមិនមែននិយាយថាគ្រូពេទ្យខ្មែរយើងមិនយកចិត្តទុកដាក់នោះទេ គឺអស់លោកទាំងនោះយកចិត្តទុកដាក់ណាស់ ខំដាក់ថ្នាំ ខំលាងមុខរបួស និង រុំវិញរាល់ៗថ្ងៃ ប៉ុន្តែដោយសារប្រទេសយើងនៅក្រខ្វះខាត ម្ល៉ោះហើយឧបករណ៍ព្យាបាលមិនទាន់ទំនើប ទើបក្រោយពេលដែលគេនាំយកម៉ារីណាទៅវៀតណាមជាបណ្តោះអាសន្ន នោះ ខ្ញុំក៏ប្រញាប់ប្រញាល់ទៅទាក់ទងជាមួយឯកអគ្គរដ្ឋទូតអាមេរិក ប្រចាំនៅកម្ពុជាភ្លាម គឺ លោក KENT WIEDEMANN ! ហើយលទ្ធផលក៏ឆ្លើយមកជាទីពេញចិត្ត ! . ."

ម្តងនេះគេឃើញ សេគុនដូ ប្រែទឹកមុខបន្តិចហាក់ដូចជាក្នុងបេះ

ដូងគេពុះពោរទៅដោយក្តីឈឺចាប់ដ៏អាថិកំបាំងមួយ ÷

-" ក្រោយដែលខ្ញុំទទួលទូរសព្ទ័ពីឪពុកម្តាយខ្ញុំ ប្រាប់ថាការវិលត្រឡប់មកពីព្យាបាលនៅវៀតណាមមួយខែ គ្មានបានជាការអីនោះខ្ញុំក៏សំរេចចិត្តពុះពារសោងកន្ត្រោងធ្វើយ៉ាងណាឱ្យប្អូន ខ្ញុំមកទីនេះឱ្យទាល់តែបាន ហើយមិនឱ្យគេត្រឡប់ទៅព្យាបាលនៅវៀតណាមវិញ តាមការសន្យារបស់គ្រូពេទ្យទាំងនោះជាលើកទីពីរ ទីបី ទៀតឡើយ ! . ម្យ៉ាងទៀតដូចលោកជ្រាបហើយ ខ្ញុំបានទាក់ទងជាមួយក្រុមហ៊ុនកែសម្ផស្ស SHRINER BURN ដែលមានទីតាំងធំនៅរដ្ឋមែសហ្សាឈូសេត យើងនេះគេល្បីល្បាញពេញសកលលោកក្នុងការកែសម្រស់សម្ផស្ស នារី ឬ បុរស ពេលនេះ គេធានាថានឹងកែសម្ផស្សម៉ារីណារយៈពេល៤ឆ្នាំ ដោយសហការជាមួយ LYNN COMMUNILY CENTER នេះ ! . . "

នៅពេលដែល សេគុនដូ ពោលចប់ អ្នកគ្រូពេទ្យក៏ឆ្លើយបញ្ជាក់បន្ថែមបន្ទាប់ពីត្រូវអ្នកយកពត៌មានសាកសួរ ÷

-" ក្រុមគ្រូពេទ្យយើង ប្តេជ្ញានឹងព្យាបាល ម៉ារីណា រហូតដល់អាយុ២១ឆ្នាំ ដោយព្យាយាមវះកាត់មុខមាត់ ព្រមទាំងសរីរាង្គរបស់នាងឱ្យមានដំណើរការស្រួលបួលឡើងវិញ ព្រោះនាងនៅជាកុមារី យ៉ាងនេះអាចមានសិទ្ធិសំរាកនៅក្នុងមន្ទីរពេទ្យដល់ទៅ៤ឆ្នាំឯណោះ ពេលនេះពួកយើងធ្វើការវះកាត់ជាលើក ទី២ហើយ នៅលើផ្ទៃកមាត់ និង ច្រមុះ ប៉ុន្តែវានឹងត្រូវការ ឆ្លងកាត់ការវះកាត់គ្រប់បែបយ៉ាងរហូតដល់ទៅ ១០០ ដង ឯណោះ ! . . "

ក្រោមស្គររដង្ហើមធំយ៉ាងវែង១ របស់ក្រុមគ្រួសារដែលនៅអង្គុយស្ងៀមចាំស្តាប់នោះ គេឃើញយុវតីអភព្វខំសម្លឹងដោយង៉យប្លែកមកកាន់អ្នកយកពត៌មាន ហាក់ដូចជាមិនចង់ឱ្យជននេះសួរអ្វីតទៅទៀត ប៉ុន្តែលោកពៅ ពន្លក នៅតែមិនអស់ចិត្តហើយសួរបន្តថា÷

-" តើនៅថ្ងៃមុខ ម៉ារីណា អាចព្យាបាលជាសះដូចដើមវិញទេ ?"

សំនួរនេះងាយស្រួលស្តាប់សោះ តែវាហាក់ដូចជាមានទម្ងន់ក្តៅក្តួលបំផុតមកលើបេះដូងរបស់នារីរងគ្រោះ ព្រមទាំងក្រុមគ្រួសាររបស់នាងហើយនាងមិនត្រឹមតែមិនចង់ឮសំនួររបស់ភ្ញៀវប៉ុណ្ណោះទេ គឺថែមទាំងមិនចង់ឮចម្លើយរបស់គ្រូពេទ្យទៀតផង ព្រោះនាងដូចជាបានដឹងខ្លួនឯងរួចជាស្រេចទៅហើយថា កម្លាំងទឹកអាស៊ីដដែលក្តៅដូចភ្លើងនោះ ពិតជាបញ្ចប់សម្ផស្សពីកំណើតរបស់នាងត្រឹមហ្នឹងហើយ ។

នៅពេលដែល ម៉ារីណា រំពឹងគិតមិនទាន់ចប់ស្រួលបួលផង ស្រាប់តែសម្លេងរបស់គ្រូពេទ្យបានលាន់ឮឡើងយ៉ាងពិរោះរណ្តំថា ÷

-" ដោយសារកំរិតជាតិគីមី ដែលចាក់ស្រោចមកលើខ្លួននាង មានចំាមពលធ្ងន់ធ្ងរពេក សម្ផស្សរបស់ ម៉ារីណា ពិតជាមិនអាចវិលទៅកាន់លំនាំដូចនៅក្នុងរូបថតរបស់នាងឡើយ ទោះជាក្រុមគ្រូពេទ្យយើងប្រឹងប្រែងយ៉ាងណាក៏ដោយ ព្រោះមុខមាត់មនុស្សយើងគ្រាន់តែមានការវះកាត់ដូរបន្តិច នោះវាពិតជាប្រែប្រួលពីលំនាំដើមបាត់ទៅហើយ !.. ប៉ុន្តែយើងធានាថានឹងមើលនាងឱ្យជាសះស្អាតលែងរលេះរលួយ គឺស្អាតនៅក្នុងសម្រស់មួយផ្សេង !.."

បទសម្ភាសន៍របស់លោក ពៅ ពន្លក អ្នកយកពត៌មានប្រចាំវិទ្យុអាស៊ីសេរីពេលនោះ ហាក់ដូចជាចប់ត្រឹមណោះ ហើយគេក៏ហាក់ដូចជាមិនបានឮជននោះសាកសួរពីរឿងភាគីមន្ត្រីដែល មានពាក់ពន្ធ័ជាមួយ ម៉ារីណា រួមទាំងជំទាវចិត្តកំណាចដែលបាន ព្រួតគ្នាធ្វើបាបនាងនោះឡើយ ប៉ុន្តែទោះបីយ៉ាងនេះក្តីក៏ សេគុនដូ បងប្រុសចិត្តមាសបានបញ្ជាក់ជាចុងក្រោយថា ÷

- " ទោះបីជាការព្យាបាលត្រូវអូសបន្លាយប៉ុន្មានឆ្នាំទៀតក៏ដោយ ក៏ខ្ញុំមានការកក់ក្តៅជាខ្លាំង ដោយបានយកប្អូនខ្ញុំមកដល់ទីនេះដែលខ្ញុំជឿជាក់ថា ប្អូនខ្ញុំលែងត្រូវទទួលការគំរាមកំហែងពីពពួកជនព្រៃផ្សៃទាំងនោះទៀតហើយ ហើយក៏ជាឱកាសឱ្យនាងដេកគិតត្រិះរិះពិចារណារៀបចំកសាងអនាគតមួយថ្មីឡើងវិញ ព្រោះដូចលោកជ្រាបស្រាប់ហើយ អនាគតរបស់ម៉ារីណា ប្អូនស្រីខ្ញុំនេះ ពិតជាមានវែងឆ្ងាយទៅមុខទៀត មិនមែនមកត្រូវបញ្ចប់នៅកណ្តាលផ្លូវ ដោយស្នាដៃមនុស្សគ្មានវិចារណញ្ញាណទាំងនោះឡើយ ហើយអ្វីៗដែលវាស្ថិតនៅជារឿងតុលាការនោះ គឺមិនប្រែប្រួលទៅណាទេ ព្រោះពួកគេប៉ុនប៉ងសំលាប់ប្អូនស្រីខ្ញុំ ដោយការគិតទុកជាមុន ( Flagrant délit ) មានភស្តុតាង និង សាក្សីជាក់ស្តែងសព្វគ្រប់ទាំងអស់ ដូច្នេះទោះបីរឿងភ្លើងនេះក្លាយទៅជាធ្យូងទៅហើយក៏ដោយ ក៏ជាធ្យូងដែលមានកំដៅជាប់ជានិច្ច ! . . "

លោក ពៅ ពន្លក ងាកមកញញឹមដាក់ សេគុនដូ ហើយបន្ទរ

ប្រយោគដោយងក់ក្បាលបណ្តើរ ÷

- " ខ្ញុំសង្ឃឹមថា ជនដែលបង្កទុក្ខវេទនាដល់ក្មេងស្រីក្នុងវ័យ១៦ ឆ្នាំនេះ មុខជាត្រូវតុលាការវិនិច្ឆ័យទោស ថ្វីបើម៉ារីណាអាចថាជាស្រីកំណាន់លួចលាក់របស់គេ ក៏ដោយសារគេបោកប្រាសកុហក់នាង ទើបនាងជឿរហូតដល់ខូចអនាគតដូច្នេះ ! . . "

ឈប់បន្តិច ទើបជននោះ បែរទៅនិយាយចំពោះអ្នកជម្ងឺ ថា ÷

- " ម៉ារីណា ពូសូមអរគុណដែលក្មួយបានឱ្យពូដឹងពីសុខទុក្ខក្នុងផ្លូវចិត្តរបស់ក្មួយ ក្រោយដែលបានមកដល់ទីនេះ សង្ឃឹមថាមិនយូរប៉ុន្មានទេ ពូនឹងមកសុំធ្វើបទសម្ភាសន៍ចំពោះក្មួយទៀតពីការវិវត្តន៍ផ្សេងៗ លើវិធីព្យាបាលរបស់គ្រូពេទ្យ . . . សូមក្មួយ . . . មានសំណាងល្អគ្រប់នាទី ហើយដំណឹងនេះពូនឹងយកទៅចុះផ្សាយនៅថ្ងៃទី ២២ មិនា នេះ ! . . . អ្នកស្តាប់វិទ្យុអាស៊ីសេរីទាំងប៉ុន្មាន មុខជាបានដឹងពីដំណើររឿងរបស់ក្មួយដែលមកដល់អាមេរិកនេះ ហើយមុខជាអាណិតអាសូរជួយគាំទ្រជាមិនខាន ! . . "

បន្ទាប់ពីនោះ ប៊ុនឈឿន សូមីរ៉ែត ក៏បានបន្លឺដែរថា ÷

- " . . ខ្ញុំបានដឹងថា បងប្អូន . . . ខ្មែរយើងដែលនៅអាមេរិកនេះ ស្មោះស្ម័គ្ររួមគ្នាជួយស្រីអូនច្រើនណាស់ . . . ព្រោះគេអាណិតនាង ! . . "

សេតុនដូ បញ្ជាក់ជាចុងក្រោយ ÷

- " មែនហើយ អ្នកស្រីម្នាក់ដែលបានជួយជ្រោមជ្រែងខ្ញុំក្នុងរឿងនេះ ក៏បានប្រាប់ខ្ញុំដែរថាមានអង្គការសមាគមគ្រួសារច្រើនកន្លែង គេនឹងបរិច្ចាគធនធានផ្ទាល់ខ្លួនដើម្បីជួយស្រីអូន ដោយរៀបចំបើកគណនីផ្ញើទុកនៅ

ធនាគារ ដោយគ្មានអ្នកណាមានសិទ្ធិបើកបានឡើយ ក្រៅពីស្រីអូនតែម្នាក់គឺគេរក្សាទុកសម្រាប់នាង ចាយវាយក្នុងការព្យាបាលនេះ ! . . "

--បន្ទាប់ពីអ្នកយកពត៌មានលាចេញទៅវិញ ម៉ារីណានៅតែសម្ងំដេកស្ងៀមចាំស្តាប់ការជជែកគ្នារបស់ក្រុមគ្រួសារនាង ប៉ុន្តែនាងហាក់ដូចជាមិនបានព្រួគនិយាយពីរឿងអ្វីតទៅទៀតឡើយ ព្រោះអារម្មណ៍នាងបានអណ្តែតចេញផុតពីរូបរាងកាយទៅហើយ ។

នៅក្នុងរណ្តៅគ្រាប់ភ្នែកទាំងគូ ដែលពោរពេញដោយទុក្ខសោកម៉ារីណា បានលើកកូនរូបថតដែលនៅក្បែរខ្នើយមកសម្លឹង ពិនិត្យសារជាថ្មី ។

អ្វីៗដែលបានកន្លងផុតទៅ តាំងពីនាងនៅតូច . . រហូតឆ្លងកាត់រឿងរ៉ាវជីវិតច្រើនជាន់ច្រើនស្រទាប់ . . បានបញ្ចាំងឡើងវិញនៅក្នុងកូនកញ្ចក់រូបថតនោះ ដូចជាខ្សែភាពយន្តមួយដែលពោរពេញដោយក្តីអនោចអធម៌ . . .